ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
**គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត**
**ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការលើកលែងបន្ធូរបន្ថយយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ចំនួន ២២៩ គ្រឿង ដែលត្រូវបានឃាត់ទុកនាពេលកន្លងមក ដោយមន្ត្រីមានសមត្ថកិច្ចប្រចាំស្ថានីយជញ្ជីងអចល័ត និងជញ្ជីងចល័ត នៃក្រសួងសាធារណការ និងដឹកជញ្ជូន

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ ដោយរាជរដ្ឋាភិបាលបាននិងកំពុងរៀបចំកែសម្រួល ដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិក្នុងបរិបទក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ដោយបានបើកឱ្យដំណើរការឡើងវិញនូវសាលារៀន ផ្សារទំនើប ផ្សារសាធារណៈ តំបន់ទេសចរណ៍ និងការស្តារសកម្មភាពធុរកិច្ច អាជីវកម្ម សេដ្ឋកិច្ច សង្គម ជាពិសេសការគាំទ្រដល់ការរស់ឡើងវិញរបស់វិស័យឯកជន និងបានលើកលែងបន្ធូរបន្ថយក៏ដូចជាផ្តល់ឱកាសសារជាថ្មីនៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរខាង មុខនេះ ដល់ម្ចាស់ក្រុមហ៊ុន និងម្ចាស់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលមន្ត្រីមានសមត្ថកិច្ចប្រចាំស្ថានីយជញ្ជីងអចល័ត និងជញ្ជីងចល័ត នៃក្រសួងសាធារណការ និងដឹកជញ្ជូន បានឃាត់ទុកនាពេលកន្លងមក គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ សូមអញ្ជើញ ម្ចាស់ក្រុមហ៊ុន និងម្ចាស់យានយន្តទាំងអស់ មកចូលរួមដោះស្រាយដូចខាងក្រោម៖

១- ម្ចាស់ក្រុមហ៊ុន និងម្ចាស់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលត្រូវបានឃាត់ទុក ហើយបានបង់ប្រាក់ពិន័យរួចរាល់ហើយនោះ អាចមកទទួលយានយន្តនៅតាមទីតាំងរក្សាទុកយានយន្ត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១៨ **ខែតុលា ឆ្នាំ២០២១** ព្រមទាំងធ្វើកិច្ចសន្យាលែងប្រព្រឹត្តបទល្មើសដឹកជញ្ជូនលើកទម្ងន់កម្រិតកំណត់ជាលើកទី២ បន្តទៀត។

២- ដោយឡែក ម្ចាស់ក្រុមហ៊ុន និងម្ចាស់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលត្រូវបានឃាត់ទុក និងមិនទាន់បង់ប្រាក់ពិន័យត្រឹមត្រូវតាមច្បាប់ ត្រូវមកដោះស្រាយ និងបង់ប្រាក់ពិន័យឱ្យបានមុន **ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ជាកំហិត** ក្នុងករណីផុតរយៈពេលនេះ គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នឹងចាត់វិធានការតាមនីតិវិធី និងបទប្បញ្ញត្តិច្បាប់ជាធរមាន។

៣- គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នឹងខិតខំធ្វើការផ្សព្វផ្សាយជូនដំណឹងឱ្យបានទូលំទូលាយបន្ថែមទៀតអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់សាធារណជនទូទៅឱ្យបានយល់ដឹង និងជ្រួតជ្រាបកាន់តែច្បាស់ រួមទាំងខិតខំបន្តការរឹតបន្តឹងអនុវត្តច្បាប់ដោយមិនយោគយល់ឬលើកលែងជាលើកទី២ទៀតឡើយ ចំពោះយានយន្តទាំងឡាយណាដែលដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

៤- រាល់ការប្រគល់-ទទួលយានយន្ត ម្ចាស់យានយន្ត ត្រូវមកទទួលយានយន្តនៅតាមទីតាំងដែលបានឃាត់ទុក គិតចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៨ **ខែតុលា ឆ្នាំ២០២១ លើកលែងតែថ្ងៃទី០៥-០៦-០៧ ខែតុលា ឆ្នាំ២០២១** ដែលជាថ្ងៃឈប់សម្រាកក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ។ ម្ចាស់យានយន្តត្រូវភ្ជាប់មកជាមួយនូវ សំណុំឯកសារ ឬលិខិតស្នាមពាក់ព័ន្ធនឹងយានយន្ត ដែលបានឃាត់ទុកនាពេលកន្លងមក ដែលចេញដោយមន្ត្រីមានសមត្ថកិច្ចប្រចាំស្ថានីយជញ្ជីងអចល័ត និងជញ្ជីងចល័ត នៃក្រសួងសាធារណការ និងដឹកជញ្ជូន។

ទទួលបានសេចក្តីជូនដំណឹងនេះ គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ សង្ឃឹមនឹងជឿជាក់ថា ម្ចាស់ក្រុមហ៊ុន និងម្ចាស់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលបានឃាត់ទុកនាពេលកន្លងមកទាំងអស់នឹងចូលរួមសហការដើម្បីធ្វើការដោះស្រាយតាមនីតិវិធីរដ្ឋបាល ដូចបានជូនដំណឹងនេះ។

ថ្ងៃ...សុ.ក្រ...១០រោច.....ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....០១....ខែ...តុលា...ឆ្នាំ២០២១